# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែកញ្ញា-តុលា ឆ្នាំ២០១៧**

**September-October 2017**

## មាតិកា

**ទំព័រ**


**ខ្លឹមសារសង្ខេប / Executive summary** ២

**១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** ៥

១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index ៥

១.២. វិស័យហិរញ្ញវត្ថុ / Finance ៦

១.៣. វិស័យពាណិជ្ជកម្ម / Trade ៨

១.៤. ការអនុវត្តថវិកា / Budget execution ៩

១.៥. វិស័យវិនិយោគឯកជន / Private investment ១០

១.៦. វិស័យទេសចរណ៍ / Tourism ១០

១.៧. វិស័យសំណង់ / Construction ១១

**២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** ១១

២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) ១១

២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) ១២

២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) ១២

**៣. ឧបសម្ព័ន្ធ** ១៤

## ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែកញ្ញា ឆ្នាំ២០១៧ បានកើនឡើង ០,៣%ធៀបនឹងខែមុន និងបានកើនឡើង ២,៧%ធៀបនឹង១ឆ្នាំមុន។ សន្ទស្សន៍ថ្លៃក្រុមទំនិញដែលបានកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងខែមុនមានដូចជា អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង សម្លៀកបំពាក់និងស្បែកជើង គមនាគមន៍ និងក្រុមទំនិញផ្សេងៗ, រីឯសន្ទស្សន៍ថ្លៃការកំសាន្តនិងវប្បធម៌បានថយចុះ ០,៤%ធៀបនឹងខែមុន។ បើធៀបនឹង១ឆ្នាំមុន សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ៤,៤%, សន្ទស្សន៍ថ្លៃភោជនីយដ្ឋានបានកើនឡើង ៧,៨%។

តាមរយៈការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ (year on year) អាចនឹងមានអត្រា ១,៩% ឬអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចនឹងមានអត្រា ២,៩%។

២. *ឥណទាន និងអត្រាការប្រាក់÷* គិតត្រឹមខែកញ្ញា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៦៤.៩៦១ប៊ីលានរៀល មានកំណើនក្នុង១ខែប្រមាណ ១,៥% ក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៧នេះ ពោលគឺប្រហាក់ប្រហែលនឹងកំណើនក្នុងឆ្នាំកន្លងទៅ។ កម្ពុជាមានកំណើនឥណទានខ្ពស់ និងរក្សាបានអត្រាឥណទានមិនដំណើរការក្នុងកម្រិតប្រហាក់ប្រហែលនឹងប្រទេសជិតខាងក្នុងតំបន់, អត្រាឥណទានមិនដំណើរការនៅកម្ពុជាស្មើ ២,៤០% វៀតណាម ២,៥% ថៃ ២,៨៣% និងហ្វីលីពីន ១,៨៩%។ អត្រាការប្រាក់នៅធនាគារពាណិជ្ជចំពោះកម្ចីជាប្រាក់រៀលនិងដុល្លារស្មើនឹង ១៤,៤៩% និង១១,៧៩% បានថយចុះបន្តិចធៀបទៅនឹងដើមឆ្នាំ ប៉ុន្តែនៅតែមានអត្រាខ្ពស់នៅឡើយ។ បន្ទាប់ពីការដាក់ឱ្យអនុវត្តប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈរបស់គណៈកម្មការមូលបត្រកម្ពុជា ធនាគារជាតិបានចេញប្រកាសស្តីពីលក្ខខណ្ឌចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការដាក់ពាក្យចុះបញ្ជីលក់មូលបត្រលើផ្សារមូលបត្រកម្ពុជា ដែលនេះនឹងជួយជំរុញដល់មធ្យោបាយហិរញ្ញប្បទានផ្ទាល់តាមរយៈការកៀរគរមូលធនពីសាធារណជន និងវិនិយោគិនផ្សេងៗ ជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុដែលមានលំហូរខ្ពស់ និងអត្រាការប្រាក់ទាបជាងប្រភពហិរញ្ញប្បទានប្រយោល។ លក្ខខណ្ឌទាំងនេះមានដូចជា មូលនិធិផ្ទាល់សុទ្ធមានចំនួនយ៉ាងតិច ៦០ប៊ីលានរៀល, អនុវត្តបានពេញលេញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា, និងមានស្ថានភាពហិរញ្ញវត្ថុនិងអភិបាលកិច្ចល្អតាមរយៈការធ្វើចំណាត់ថ្នាក់ដោយធនាគារជាតិត្រឹមកម្រិតសុវត្ថិភាពចាប់ពី ២ឆ្នាំឡើង, និងមានការអនុញ្ញាតពីធនាគារជាតិជាដើម។ កត្តានេះក៏នឹងជួយពង្រឹងទំនុកចិត្តមហាជនចំពោះមូលបត្រនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើការបោះផ្សាយមូលបត្រផងដែរ។

*ការផ្គត់ផ្គង់រូបិយវត្ថុ÷* គិតត្រឹមខែកញ្ញា រូបិយវត្ថុទូទៅ M2 បានកើនដល់ ៦៩.៧៤២ប៊ីលានរៀល ដោយមានកំណើនជាមធ្យមប្រចាំខែ ២,១%ក្នុងរយៈពេល៩ខែឆ្នាំ២០១៧នេះ (ឆ្នាំ២០១៦មានកំណើនមធ្យមប្រចាំខែ ១,៤%), ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានចំនួន ៥៨.២៦៣ប៊ីលានរៀល មានកំណើនជាមធ្យមប្រចាំខែ ២,២%។ ដុល្លារូបនីយកម្មមានគុណសម្បត្តិមួយចំនួនចំពោះសេដ្ឋកិច្ច ដូចជាការជួយរក្សាអតិផរណាឱ្យស្ថិតក្នុងកម្រិតទាប រក្សាលំនឹងអត្រាប្តូរប្រាក់ ទាក់ទាញវិនិយោគទុនពីបរទេស និងជាកត្តាជំរុញពាណិជ្ជកម្មទៅកាន់ពិភពលោកជាដើម, រីឯគុណវិបត្តិសំខាន់ៗមានដូចជាការខាតបង់ចំណូលក្នុងការបោះពុម្ពប្រាក់ជាតិ បាត់បង់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និងបាត់បង់មោទនភាពនិមិត្តរូបមួយនៃជាតិជាដើម។

៣. *ការនាំចូល៖* ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៧នេះ ការនាំចូលមានចំនួន ១០.១៩១លានដុល្លារ បានកើនឡើង ១១,៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះការនាំចូលមុខទំនិញវាយនភ័ណ្ឌកើនឡើង ៦,៣% ការនាំចូលបរិក្ខារសំណង់កើនឡើង ១២,៧% ដោយឡែកការនាំចូលប្រេងឥន្ធនៈបានថយចុះ ២៩,៧%។ *ការនាំចេញ៖* ក្នុងយៈពេល៩ខែ ឆ្នាំ២០១៧នេះ ការនាំចេញមានចំនួន ៨.២៦១លានដុល្លារ បានកើនឡើង ៦,៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ក្នុងនោះការនាំចេញផលិតផលវាយនភ័ណ្ឌនិងស្បែកជើងកើនឡើង ៥,៨% និងការនាំចេញផលិតផលកៅស៊ូធម្មជាតិកើនឡើង ៧៣,៨% (គិតជាបរិមាណកៅស៊ូនាំចេញ កើនឡើង ២៥,៦%)។

៤. ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៧នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបានចំនួន ១២.២៧៨ប៊ីលានរៀល (លើសផែនការថវិកាប្រចាំឆ្នាំ ៣,៥%) បានកើនឡើង ១៣,៧%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះចំណូលសារពើពន្ធអនុវត្តបាន ១០.៨១៨ប៊ីលានរៀល បានកើនឡើង ១៤,២%។ ចំណាយថវិកាសុរបរដ្ឋបាលថ្នាក់ជាតិមានចំនួន ១១.៣៦៧ប៊ីលានរៀល(ទាបជាងច្បាប់ថវិកា ១៦,៨%) បានកើនឡើង ៨,១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៧នេះ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៣.៨០៥ប៊ីលានរៀល និងតុល្យភាពថវិកាសុរបមានអតិរេកសាច់ប្រាក់ ៧៩២ប៊ីលានរៀល។

៥. សរុបក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគដែលបានអនុញ្ញាតមានចំនួន ១០៣គម្រោង អាចបង្កើតការងារបាន ១២២ពាន់នាក់, គិតជាទុនវិនិយោគ ៤.៨៤៣លានដុល្លារ បានកើនឡើង ៧៥,១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះមានការកើនឡើងខ្លាំងលើការវិនិយោគក្នុងវិស័យកសិកម្ម សេវាកម្ម និងទេសចរណ៍។

៦. ក្នុងខែកញ្ញា ឆ្នាំ២០១៧ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានប្រមាណ ៣៧៦ពាន់នាក់ បានថយចុះ ១១,៩%ធៀបនឹងខែសីហាកន្លងទៅ និងខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ៨,៩%។ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានបម្រែបម្រួលជារដូវកាលដែលជាទូទៅមានការប្រែប្រួលតិចតួចចាប់ពីខែមេសា ដល់ខែកញ្ញា ដោយសារលក្ខខណ្ឌអាកាសធាតុ និងមានកំណើនខ្ពស់ចាប់ពីខែតុលា ដល់ខែកុម្ភៈនៃឆ្នាំបន្ទាប់។ ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៧នេះ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិសរុបមាន ៣.៩១៣ពាន់នាក់ បានកើនឡើង ១១,៥%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៧. សរុបរយៈពេល១០ខែ ឆ្នាំ២០១៧នេះ សំណើសាងសង់សរុបមាន ២.៨១៦គម្រោង បានកើនឡើង ៦២៦គម្រោងធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំមុន, គិតជាតម្លៃសាងសង់សរុប ៦.២៦៨លានដុល្លារ បានកើនឡើង ២៧,៧%, ប៉ុន្តែគិតជាផ្ទៃក្រឡាសាងសង់សរុបមាន ១០.៣៦១ពាន់ម៉ែត្រការ៉េ បានថយចុះ ២,១%។

៨. *ថ្លៃប្រេងឆៅ* ថ្លៃប្រេងឆៅបានបន្តកើនឡើងជាបន្តបន្ទាប់គិតចាប់ពីខែកក្កដាមក។ ក្នុងខែតុលានេះ ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេងBrentថ្លៃ ៥៧,៦ដុល្លារ/ធុង និងប្រេងWTIថ្លៃ ៥១,៦ដុល្លារ/ធុង។ កំណើនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០១៧ ត្រូវបានព្យាករណ៍មានអត្រា ៣,៧% និងសម្រាប់ឆ្នាំ២០១៨ មានអត្រា ៣,៧% (ក្នុងខែមុនកំណើនព្យាករណ៍សម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨ មានអត្រា ៣,៦% និង៣,៥%)។ យោងតាមរបាយការណ៍ប្រចាំខែវិច្ឆិការបស់ OPEC បរិមាណផលិតកម្មប្រេងពិភពលោកក្នុងខែតុលាស្មើ ៩៦,៧១លានធុង/ថ្ងៃ គឺបានកើនឡើង ០,៥៣លានធុង/ថ្ងៃធៀបនឹងខែមុន, ក្នុងនោះបរិមាណផ្គត់ផ្គង់របស់ប្រទេសមិនមែន OPEC ស្មើ ៦៤,១២លានធុង/ថ្ងៃ និងប្រទេស OPEC ស្មើ ៣២,៥៩លានធុង/ថ្ងៃ។ តម្រូវការប្រេងពិភពលោកក្នុងឆ្នាំ២០១៧ ប៉ាន់ស្មានមានប្រមាណ ៩៦,៩ធុង/ថ្ងៃ

គឺបានកើនឡើងបន្តិចដោយសារសេដ្ឋកិច្ចប្រទេសចិនក្នុងត្រីមាសទី៣កន្លងទៅមានស្ថានភាពល្អជាងការរំពឹងទុក និងតម្រូវការក្នុងឆ្នាំ២០១៨រំពឹងថានឹងកើនឡើងដល់ ៩៨,៥លានធុង/ថ្ងៃ។ ជារួម ការផ្គត់ផ្គង់ប្រេងពិភពលោកមានកម្រិតទាបជាងតម្រូវការក្នុងត្រីមាសទី២និងទី៣ឆ្នាំ២០១៧នេះ ហើយគម្លាតនេះបានរីកធំក្នុងត្រីមាសទី៣។ ក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៧ កម្ពុជាបាននាំចូលប្រេងសាំង ៤០៥ពាន់តោន និងប្រេងម៉ាស៊ូត ៩៥៥ពាន់តោន បានកើនឡើងរៀងគ្នា ១០,៣% និង២,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

*ថ្លៃអង្ករ* ក្នុងខែតុលា ឆ្នាំ២០១៧ *(១)អង្ករកម្ពុជា* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤៣៥ដុល្លារ/តោន ពុំមានការប្រែប្រួលទេធៀបទៅនឹងខែមុន។ ក្នុងរយៈពេល ៩ខែឆ្នាំ២០១៧នេះ កម្ពុជាបាននាំចេញអង្ករសរុប ៣៨៥ពាន់តោន បានកើនឡើង ៩,០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៩៤ដុល្លារ/តោន បានថយចុះ ៨ដុល្លារ/តោនធៀបនឹងខែមុន។ ថ្លៃអង្ករនាំចេញរបស់ថៃបានថយចុះក្នុងខែតុលានេះដោយសារមានការបន្ថយបញ្ជាទិញដោយរង់ចាំអង្ករដែលទើបប្រមូលផលចូលក្នុងទីផ្សារ ប៉ុន្តែថ្លៃអង្ករបានមានលំនឹងមកវិញនៅចុងខែ បន្ទាប់ពីការប៉ះពាល់លើការប្រមូលផលនៅតំបន់មួយចំនួនដោយសារទឹកជំនន់។ *(៣)អង្ករវៀតណាម* អង្ករនាំចេញ(ខ្ទេច ៥%)ថ្លៃ ៣៧៦ដុល្លារ/តោន បានថយចុះប្រមាណ ៦ដុល្លារ/តោនធៀបនឹងខែមុន។ ថ្លៃអង្ករនាំចេញរបស់វៀតណាម និងថៃ បានថយចុះក្នុងខែតុលានេះ ខណៈដែលថ្លៃអង្ករនាំចេញរបស់សហរដ្ឋអាមេរិកបានបន្តកើនឡើង។ បរិមាណផ្គត់ផ្គង់អង្កររបស់ពិភពលោកសម្រាប់ឆ្នាំ២០១៧-២០១៨ត្រូវបានប៉ាន់ស្មានមានចំនួន ៤៨១,២លានតោន (តិចជាងឆ្នាំមុន ៥,៩លានតោន) និងបរិមាណតុល្យការអង្ករស្តុករបស់ពិភពលោកសម្រាប់ឆ្នាំ២០១៧/១៨ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ១៣៨,៩លានតោន គឺមានកម្រិតខ្ពស់បំផុតគិតចាប់ពីឆ្នាំ២០០០/០១ ដែលមានចំនួន ១៤៦,៧លានតោន។ បរិមាណពាណិជ្ជកម្មអង្ករពិភពលោកឆ្នាំ២០១៧ត្រូវបានប៉ាន់ស្មានមាន ៤៤,៦លានតោន កើនឡើង ១១% ធៀបទៅនឹងឆ្នាំមុន, គាំទ្រដោយកំណើនការនាំចូលអង្កររបស់ប្រទេសបង់ក្លាដែស ចិន អ៊ីរ៉ង់ ម៉ាដាហ្គាស្កា នីហ្សេរីយ៉ា ហ្វីលីពីន អារ៉ាប់ប៊ីសាអូឌីត និងស្រីលង្កា។

*ថ្លៃកៅស៊ូ* ទោះជាថ្លៃប្រេងឆៅមានការកើនឡើងក្តី ថ្លៃកៅស៊ូធម្មជាតិបានថយចុះក្នុងខែតុលានេះ។ ក្នុងខែតុលានេះ ផលិតកម្មកៅស៊ូធម្មជាតិបានកើនឡើងមកវិញនៅប្រទេសចិន និងប្រទេសផលិតកៅស៊ូមួយចំនួនក្នុងតំបន់អាស៊ានថិតក្នុងរដូវកាលប្រមូលផលខ្ពស់។ យោងតាមសមាគមប្រទេសផលិតកៅស៊ូធម្មជាតិ ANRPC ក្នុងរយៈពេល១០ខែឆ្នាំ២០១៧នេះ បរិមាណកៅស៊ូធម្មជាតិពិភពលោកផលិតបាន មានចំនួន ១០,៤៣លានតោន បានកើនឡើង ៥,០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, និងបរិមាណតម្រូវការប្រើប្រាស់មានចំនួន ១០,៧៣លានតោន បានកើនឡើង ១,១%។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងនាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Construction Approval in Nationwide (0000m2)**




Source: Min. LMUC

**Tourist Arrivals ('000 persons)**



Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបម្រុងបរទេស (Inflation, M2 and Foreign Reserve)

### Net Foreign Reserve (Mn US$)




Source: NBC

### Inflation (Montly)




Source: NIS

### Inflation (Annual)




Source: NIS

### Inflation of Main Group Items (monthly)




Source: NIS

### Inflation of main group Items (Year on Year)




Source: NIS

### Broad Money M2 (Bn KHR)




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)




Source: NBC




Source: NBC




Source: NBC




Source: NBC




Source: NBC




*Source: Cambodia Securities Exchange*

# ការអនុវត្តថវិកា (Budget)


















# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs Dept.

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

**រៀបចំដោយ នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*